# ផូស៊ីលដើមឈើភ្នំដងទង់
# ដែនជម្រកសត្វព្រៃ «ព្រៃឡង់»

ភ្នំដងទង់ ជាកូនភ្នំតូចមួយ មានកំពស់ប្រមាណ២០ម៉ែត្រ ហាក់ដូចជាទួលមួយ។ ទីតាំងនេះស្ថិតនៅខាងកើតស្ទឹងសែនប្រមាណ៣,២គីឡូម៉ែត្រ និង២គីឡូម៉ែត្រ ខាងលិច ព្រំប្រទល់ខេត្តកំពង់ធំ ក្នុងស្រុកសណ្ដាន់។ តាមរយៈការផ្ដល់ព័ត៌មានពីមន្ទីរបរិស្ថានខេត្តព្រះវិហារអំពីទីតាំងផូស៊ីលឈើ នៅកំឡុងខែតុលានេះ ក្រុមការងារសិក្សាផូស៊ីលនាយកដ្ឋានតំបន់បេតិកភណ្ឌ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន បានចុះសិក្សាបឋមលើផូស៊ីលដើមឈើថ្មដែលអាចជាប្រភេទដើមគគីរ។ ទីតាំងផូស៊ីលឈើនេះគឺស្ថិតនៅភ្នំដងទង់ ភូមិស្រែ ឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ ក្នុងភូមិសាស្ត្រដែនជម្រកសត្វព្រៃ «ព្រៃឡង់»(រូបលេខ១)។

តាមរយៈផែនទីភូគព្ភសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជាឃើញភ្នំដងទង់ដែលជាទីតាំងរកឃើញផូស៊ីលឈើ គឺមានកំណត់សំគាល់ដោយអក្សរ $T_3$ $J_2ss$ ដែលស្ថិតនៅស័កទី២ ( Mesozoic Eira ) មានអាយុកាលចន្លោះ ៦៥,៥ទៅ២៥១លានឆ្នាំ។ បើយើងពិនិត្យទៅលើសម័យកាលវិញវាស្ថិតចន្លោះសម័យកាល ទ្រីយ៉ាស៊ីក (Triassic Period) និងសម័យកាលជូរ៉ាស៊ីក (Jurassic)[៧] ដែលមានអាយុចន្លោះ ១៦១.២ទៅ២៥១លានឆ្នាំ។ ចំពោះទីតាំងផ្ទាល់យើងបានពិនិត្យឃើញថា មាន២ស្រទាប់ ដោយស្រទាប់ទី១ជាស្រទាប់ដីផ្នែកខាងលើ សំបូរដោយពពួកគ្រួសអាចម៍ផ្កាយ ដែលបង្ហាញពីការចាក់បង្គរដោយសារកំលាំងទឹកហូរនាំគ្រួសមកចាក់បង្គរនៅទីនោះក្នុងពេលណាមួយ។ ស្រទាប់ទី២ស្ថិតនៅក្រោមស្រទាប់ទី១ជាប្រភេទដីឥដ្ឋដែលចាក់បង្គរនៅទីនោះ។ ក្នុងនោះផូស៊ីលឈើ ត្រូវបានប្រទះឃើញ ដោយលេចចេញជាបំណែកតូចៗ នៅរាយបាយនៅលើដី និងតាមផ្លូវទឹកហូរ វាអាចស្ថិតនៅស្រទាប់ទី១ ឬទី២។ បើពិនិត្យលើបាតុភូត គួរតែស្ថិតនៅក្នុងស្រទាប់ទី២ ដោយហេតុថាស្រទាប់ដីឥដ្ឋ អាចជួយឱ្យដើមឈើក្លាយទៅជាថ្មបាន។ ក្នុងករណីនេះ គឺតម្រូវឱ្យមានការ

---

[៧] General Department of Mineral Resource, 2010, Geological Map of Cambodia

ធ្វើកំណាយស្រាវជ្រាវមួយ ដើម្បីសិក្សាឈ្វេងយល់ឱ្យកាន់តែច្បាស់ពីវិវត្តិដើមឈើទៅជាផូស៊ីល។ ផូស៊ីលឈើដែលបានរកឃើញនេះ គឺមាន៣ទីតាំង ដោយទីតាំងទី១ ជាបំណែកដើមឈើថ្មមួយកង់មានស្នាកស្នាមជាមែកឈើ និងស្នាកស្នាមមុខកាត់ទទឹងមានទំហំ ៤០ គុណ៦០ស.ម (រូបលេខ២-៤)។ ផូស៊ីលឈើទីតាំងទី២ នៅចំងាយប្រមាណ១០០ម៉ែត្រពីទីតាំងទី១ ជាទីតាំងរណ្ដៅដែលត្រូវបានគេកាយយកផូស៊ីលដើមឈើចេញ នៅសល់មួយដុំកប់ក្នុងដីដែលមានល្បាយគ្រួសអាចម៍ផ្កាយ បើតាមការពិនិត្យ ផូស៊ីលដើមឈើថ្មនេះអាចមានធំ ប្រសិនមានការកាយចេញ (រូបលេខ៥)។ ទីតាំងផូស៊ីលឈើទីតាំងទី៣ ជាទីតាំងផូស៊ីលនៃដើមឈើថ្មទាំងមូលបាក់ជាកង់ៗជាច្រើនដុំ ដែលមានមុខកាត់៧០ទៅ៨០ស.ម ដែលបានលេខចចេញមកលើដី ប្រសិនមានការសំអាតឬកំណាយ ទីតាំងនេះអាចនឹងជួបផូស៊ីលឈើទាំងមូល (រូបលេខ៦)។ ក្រៅពីនេះយើងក៏ឃើញមានបំណែកផូស៊ីលឈើតូចៗជាច្រើនក្នុងបរិវេណប្រមាណ៣០០ម៉ែត្រ ដែលត្រូវបានបាក់បែក និងលេចចេញនៅលើស្រទាប់ដីក្នុងតំបន់នោះដែរ។

ជារួមប្រភេទផូស៊ីលដើមឈើថ្មដែលយើងប្រទះឃើញនេះ គឺមានពណ៌ក្រម៉ៅមានរង្វង់ចិញ្ចៀនកាត់ទទឹងឈើថ្ម មានលក្ខណៈធំៗ ប្រហាក់ប្រហែលផូស៊ីលដើមឈើដែលយើងបានធ្វើកំណាយស្រាវជ្រាវដែលរកឃើញនៅដែនជម្រកសត្វព្រៃលំផាត់ ខេត្តរតនគិរី ដែលក្រុមការងារសិក្សាផូស៊ីលកាលពីឆ្នាំ២០១៩-២០ កន្លង។[២] ចំពោះទីតាំងភូគព្ភសាស្ត្រក៏មានអាយុកាលដូចគ្នា ហើយផូស៊ីលដើមឈើថ្មនៅលំផាត់ស្ថិតក៏មានស្រទាប់ដីឥដ្ឋផងដែរ។ ការរកឃើញស្ថានីយផូស៊ីលដើមឈើថ្មីមួយកន្លែងទៀតនៅលើទីតាំងភ្នំដងទង់ ដែលនេះជាទិន្នន័យ និងព័ត៌មានថ្មីដ៏សំខាន់មួយដែលយើងគួរសិក្សាស្រាវជ្រាវជាបន្តនៅថ្ងៃក្រោយ ដើម្បីបង្កើតបានជាទិន្នន័យ និងចងក្រងទុកជាឯកសារសម្រាប់ការសិក្សាផូស៊ីលនៅប្រទេសកម្ពុជានាពេលអនាគត៕

[២] https://ams.com.kh/khmercivilization/detail/3629

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ១



រូបលេខ២

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៣



រូបលេខ២៤

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៥



រូបលេខ២៦

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ